រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

022KH01A-01

ការប្រតិបត្តិតាមព្រះគ្រីស្ត



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

២២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

អធិស្ឋាន ទូលសូមអោយព្រះជាម្ចាស់ប្រើអត្ថបទសិក្សានេះ ដើម្បីអោយអ្នក និងក្រុមជំនុំរបស់អ្នកអាចប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូគ្រីស្ត ។

នៅក្នុងម៉ាថាយ ២៨:១៨-២០ ព្រះយេស៊ូបង្គាប់យើងថា÷
«ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ។ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេឱ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក » ។

ព្រះយេស៊ូបង្គាប់អោយយើងបង្រៀនអ្នកជឿថ្មី អោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអង្គ ។ ឧទាហរណ៍ : នៅពេលរសៀលថ្ងៃអាទិត្យ គ្រួគង្វាលទៅសួរសុខទុក្ខ និងបង្រៀនអ្នកជឿថ្មី គឺសារឿន និងនាងម៉ារី...។

កំណត់ចំណាំ

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនសមាជិកក្រុមជំនុំ ឬ ក្រុមរបស់អ្នក (ជាពិសេស អ្នកជឿថ្មី) អោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ ។ ការប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ ជាជំហានដំបូងរបស់ជីវិតគ្រីស្តជន ។

កំណត់ចំណាំ



អ្នកទាំងពីរបានសង្គ្រោះ ដោយសារជំនឿ តាមរយៈសេចក្តីស្រឡាញ់ដ៏ធំធេងរបស់ព្រះជាម្ចាស់ពិតមែន គឺថាដោយសារព្រះហឫទ័យប្រណីសន្តោស ដែលយើងមិនសក្តិសមនឹងទទួល ។ ប៉ុន្តែ ការសង្គ្រោះរបស់អ្នកត្រូវបង្កើតផលផ្លែ ។ ក្នុងដំណឹងល្អយ៉ូហាន ព្រះយេស៊ូមានព្រះបន្ទូលប្រាប់ថា៖“ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ” ។ ធ្វើដូចនេះ អ្នកនឹងក្លាយជាសាវ័ក ដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត គឺមិនមែនជាអ្នកជឿ ដែលគ្រាន់តែស្តាប់ តែមិនធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ ។ ជំនឿដែលគ្មានការប្រព្រឹត្តអំពើល្អជាជំនឿស្លាប់ (យ៉ាកុប ២:២៦) ។



៤- តើអ្នកថ្វាយដង្វាយដោយចិត្តរីករាយ និងចិត្តសប្បុរសដែរឬទេ ?

☐ ជាក់ ។

☐ មិនជាក់ទេ ។ ប៉ុន្តែ ខ្ញុំនឹងចាប់ផ្តើម ។

៥- តើអ្នកចូលរួមធ្វើពិធីកាច់នំប៉័ងជាមួយក្រុមជំនុំរបស់អ្នកដែរឬទេ ?

☐ ចូលរួម ។

☐ មិនបានចូលរួមទេ ។ ប៉ុន្តែ ខ្ញុំនឹងចាប់ផ្តើម ។

៦- តើអ្នកបានបែរចេញឈប់ធ្វើអំពើបាប ដែលអ្នកដឹងខ្លួនថាបានប្រព្រឹត្ត ដោយមានព្រះជាម្ចាស់ជួយដែរឬទេ ?

☐ បាន ។

☐ ខ្ញុំនឹងធ្វើ ។

© Project WorldReach © SEAN

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- តើអ្នកចាំភារៈកិច្ចទាំងប្រាំពីររបស់សមាជិកក្រុមជំនុំដែរឬទេ ?

☐ ចាំ ។

☐ ខ្ញុំមិនចាំទេ ប៉ុន្តែ ខ្ញុំនឹងទន្ទេញអោយចាំឥឡូវនេះ ។

២- តើអ្នកអធិស្ឋាន ហើយអាន និងរិះគិតពិចារណាពីព្រះបន្ទូលព្រះជាម្ចាស់ជារៀងរាល់ថ្ងៃដែរឬទេ ?

☐ ខ្ញុំអធិស្ឋាន និងអានព្រះគម្ពីររាល់ថ្ងៃ ។

☐ ខ្ញុំមិនបានអធិស្ឋាន និង អានទេ ប៉ុន្តែ ខ្ញុំនឹងចាប់ផ្តើម ។

៣- តើអ្នកផ្សាយដំណឹងល្អ ជាទៀងទាត់ដែរឬទេ ?

☐ ផ្សាយ ។

☐ ខ្ញុំនឹងចាប់ផ្តើម ។

ហេតុអ្វីបានជាគ្រីស្តជនប្រព្រឹត្តអំពើល្អ ?

☐ ដើម្បីអោយបានសង្គ្រោះ ។

☐ ដើម្បីប្រតិបត្តិតាមព្រះគ្រីស្ត ដោយសេចក្តីស្រឡាញ់ ។

☐ ដើម្បីសន្សំកុសលផលបុណ្យ ។

យើងធ្វើអំពើល្អ ដើម្បីឱ្យបានក្លាយជាសាវ័កដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត ។ អ្នកបំរើរបស់ព្រះអង្គប្រតិបត្តិតាមព្រះអង្គ ដោយសេចក្តីស្រឡាញ់ ។



© Project WorldReach © SEAN

ខ្ញុំបានសរសេរសេចក្តីបង្គាប់សំខាន់ៗខ្លះរបស់ព្រះយេស៊ូ-
គ្រីស្ត នៅលើក្រដាសនេះ ។



១- កែប្រែចិត្តគំនិត ជឿ និងទទួលព្រះវិញ្ញាណ-
ដ៏វិសុទ្ធ (ការសង្គ្រោះ) ។

២- ទទួលពិធីជ្រមុជទឹក (ចាប់ផ្តើមរស់នៅដោយ
មានជីវិតថ្មី) ។

៣- ស្រឡាញ់ព្រះជាម្ចាស់ និងអ្នកឯទៀត ។

៤- អធិស្ឋាន និងរៀនព្រះបន្ទូលព្រះជាម្ចាស់ ។

៥- ជួបជុំគ្នា និងធ្វើពិធីកាច់នំបុ័ង ។

៦- ចែកចាយ និងថ្វាយដង្វាយ ។

៧- បង្កើតសាវ័ក ដោយផ្សាយដំណឹងល្អ និងបង្រៀន
ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

ជំរាបលា ។



ជំរាបលា លោកគ្រូ ។

© Project WorldReach © SEAN

បើសិនជាគ្រីស្តជនណាម្នាក់ប្រព្រឹត្តអំពើបាបអ្វីមួយ តើជំបូង អ្នកត្រូវធ្វើដូចម្តេច ?

□ និយាយប្រាប់គ្រីស្តជនឯទៀត អំពីអំពើបាបរបស់គាត់ ។

□ អធិស្ឋានសំរាប់គាត់ ហើយនិយាយជាមួយគាត់ផ្ទាល់ ។

បើសិនជាមានអ្នកណាម្នាក់ធ្វើខុសមកលើយើង យើងត្រូវអធិស្ឋានឱ្យគាត់ ហើយទៅនិយាយជាមួយគាត់ សាត់ៗ តែពីរនាក់ ។ ការដើរទៅនិយាយអំពីអ្នកណាម្នាក់ដែលធ្វើខុស ប្រាប់អ្នកឯទៀតច្រើននាក់ ជាកំហុសធន់ណាស់ (ម៉ាថាយ ៧:១-៥, យ៉ាកុប ជំពូក ៣) ។







តើរបៀបបំរើព្រះជាម្ចាស់ណាមួយ ដែលប្រសើរជាងគេ ?

☐ បំរើតែម្នាក់ឯង ។

☐ បំរើរួមគ្នាជារូបកាយតែមួយ ។

☐ បំរើតែជាមួយគ្រូគង្វាលប៉ុណ្ណោះ ។

យើងបំរើព្រះជាម្ចាស់រួមគ្នាជារូបកាយតែមួយ ។ ព្រះជាម្ចាស់បង្គាប់ពួកអ្នកជឿអោយជួបជុំគ្នា ដើម្បីថ្វាយបង្គំ ដោយសេចក្តីស្រឡាញ់ (ហេប្រឺ ១០:២៤-២៥) ។



យើងប្រៀនប្រដៅគ្រីស្តជនដែលធ្វើខុស ។ ដំបូងយើងនិយាយជាមួយពួកគេដោយចិត្តស្លូតបូត (កាឡាទី ៦:១) ។ បើសិនជាពួកគេមិនស្តាប់ យើងនឹងនាំសមាជិកផ្សេងម្នាក់ ឬពីរនាក់ទៅជាមួយ ដើម្បីជាស់តឿនគេ ។ បើសិនជាបងប្អូននោះមិនកែប្រែចិត្តគំនិតទេ យើងនឹងប្រាប់ក្រុមជំនុំទាំងមូល ។ បើសិនជាគេមិនស្តាប់ទៀត យើងនឹងអោយគេចេញពីក្រុមជំនុំ តាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត (ម៉ាថាយ ១៨:១៥-២០)។




អរគុណ ម៉ារី ។ នេះពិតជាបង្ហាញពីសេចក្តីស្រឡាញ់
របស់ព្រះគ្រីស្តមែន ! ។
លោកគ្រូ ខ្ញុំសូមសួរសំណួរមួយទៀតសិន ។ តើ
ក្រុមជំនុំធ្វើដូចម្តេច បើសិនជាអ្នកជឿណាម្នាក់ធ្វើខុស
ខ្លាំងមែនទែន ?


តើកីឡាករណាមួយ ដែលគ្មានវិន័យ ?
ខ្ញុំយល់ហើយ ។
ចុះអ្នកជឿណាខ្លះ ដែលគ្មានវិន័យនៅក្នុងក្រុមជំនុំនេះ ?
ម្នាក់ដែលលេងជាមួយឆ្កែ ។

ហេតុអ្វីបានជាព្រះគ្រីស្តធ្វើអោយក្រុមជំនុំរបស់ព្រះអង្គ
ទៅជារូបកាយតែមួយ ?



ដើម្បីឲ្យយើងអាចផ្សព្វផ្សាយដំណឹងល្អអំពីព្រះគ្រីស្តដល់
ពិភពលោកទាំងមូល (កិច្ចការ ១:៨) និង ក្លាយជា
ពន្លឺបំភ្លឺ មនុស្សទាំងអស់ (ម៉ាថាយ ៥:១៤) ។
យើងមិនអាចធ្វើកិច្ចការទាំងនេះតែឯងបានទេ ។
យើងអាចធ្វើកិច្ចការគ្រប់យ៉ាងបាន ដោយរួមគ្នាក្នុង
ព្រះគ្រីស្ត ជារូបកាយតែមួយ ដែលមានការអប់រំល្អ ។

ល្ងាចហើយ ខ្ញុំទៅវិញហើយ ។



លោកគ្រូ កុំអាលទៅ យើងមានអំណោយបន្តិចបន្តួច
ជូនលោកគ្រូ ។ នេះជាផ្លែឈើសំរាប់គ្រួសារលោក
គ្រូ ។ យើងស្រឡាញ់គ្រួសាររបស់លោកគ្រូណាស់ ។

ដើម្បីអោយសមាជិកក្រុមជំនុំរួមប្រកបល្អជាមួយគ្នាជានិច្ច យើងត្រូវ :

☐ អោយគ្រប់គ្នាជឹង ពេលអ្នកដឹកនាំធ្វើខុស ។

☐ ជួយមនុស្សអោយច្រៀងស៊ីសង្វាក់គ្នា ។

☐ ផ្គត់ផ្គង់គ្រួគង្វាលស្មោះត្រង់របស់យើង ។

យើងត្រូវផ្គត់ផ្គង់គ្រួគង្វាលរបស់យើង ។ បើសិនជាគ្មានការគោរពចំពោះអ្នកដឹកនាំក្រុមជំនុំទេ ក្រុមជំនុំក៏មិនស្ថិតមានប្រសិទ្ធិភាពដែរ ។ យើងត្រូវអធិស្ឋានសំរាប់ពួកអ្នកដឹកនាំ ស្តាប់តាមពួកគេ និង ផ្គត់ផ្គង់លុយកាក់ដល់ពួកគេ បើអាចធ្វើបាន ។

(ហេប្រឺ ១៣:១៦-១៨)





តើសេចក្តីមួយណាសំខាន់ជាងគេ ?

☐ **បង្រៀនអោយចេះអាន ។**

☐ **បង្រៀនអោយចេះដាក់ដង្វាយដប់ភាគរយ ។**

☐ **នាំមនុស្សបាបអោយទទួលជឿព្រះគ្រីស្ត ។**

បេសកកម្មសំខាន់បំផុតដែលក្រុមជំនុំត្រូវធ្វើ គឺនាំពិភពលោកឱ្យទទួលជឿព្រះគ្រីស្ត ដើម្បីអោយមនុស្សដែលបាត់បង់ថ្វាយខ្លួនទៅព្រះគ្រីស្ត និងទទួលជីវិតអស់កល្ប ។



ពួកគេទាំងពីរនាក់នៅតែបានសង្គ្រោះ តែព្រះគ្រីស្ទនឹងវិនិច្ឆ័យការប្រព្រឹត្តរបស់ពួកគេ ។ ពួកគេខ្វះសេចក្តីស្រឡាញ់ចំពោះព្រះយេស៊ូគ្រីស្ត ។



ដ្បិតព្រះអង្គមានព្រះបន្ទូលថា៖ “បើអ្នករាល់គ្នាប្រព្រឹត្តតាមសេចក្តីដែលខ្ញុំបានបង្គាប់មក អ្នករាល់គ្នាពិតជាមិត្តសំឡាញ់របស់ខ្ញុំមែន” (យ៉ូហាន ១៥:១៤) ។ យើងត្រូវស្តាប់បង្គាប់ព្រះអង្គ មិនមែនព្រោះតែយើងភ័យខ្លាចព្រះអង្គដាក់ទោសទេ ។ ប៉ុន្តែ ដោយសារយើងស្រឡាញ់ព្រះអង្គ និងចង់ថ្វាយកិត្តិយសទៅព្រះអង្គ ។

ខ្ញុំមិនអាចចេញទៅភូមិឆ្ងាយៗ ដើម្បីផ្សាយដំណឹងល្អទេ ។



តែប្អូនអាចជាក់ជង្វាយដប់ភាគរយ ។ ការនេះធ្វើឱ្យក្រុមជំនុំអាចផ្តល់ផ្តង់អ្នកផ្សាយដំណឹងល្អ ដែលចេញទៅធ្វើការនៅកន្លែងឆ្ងាយៗ ។ ព្រោះយើងធ្វើការរួមគ្នាជារូបកាយតែមួយ (១ ធីម៉ូថេ ៥:១៧-១៨) ។

តែបើទុកអោយតែគ្រូគង្វាលផ្សាយដំណឹងល្អ ប្រហែលជាប្រសើរជាង ព្រោះលោកគ្រូយល់កិច្ចការច្រើនជាង ។



មិនមែនទេម៉ារី ។ ការធ្វើទីបន្ទាល់ ឬផ្សាយដំណឹងល្អជាបេសកកម្មរបស់ក្រុមជំនុំទាំងមូល និងរបស់សមាជិកម្នាក់ៗ (កិច្ចការ ៨:៤) ។ យើងទាំងអស់គ្នាមិនមែនមានអំណោយទានដូចគ្នាទេ តែយ៉ាងហោចណាស់ក៏ប្អូនស្រីអាចនិយាយប្រាប់កូនៗ និងមិត្តភក្តិរបស់ប្អូនដែរ ។

យើងបានសង្គ្រោះរួចពីការកោត់ទោសមកពីវិន័យ និងការវិនិច្ឆ័យទោសចុងក្រោយរបស់ព្រះជាម្ចាស់ ។ ប៉ុន្តែ មានការវិនិច្ឆ័យមួយផ្សេងទៀត ដែលសំរាប់តែគ្រីស្តបរិស័ទ គឺព្រះអម្ចាស់យេស៊ូនឹងប្រទានរង្វាន់តាមអំពើដែលយើងប្រព្រឹត្ត ។ អំពើទាំងនោះនឹងត្រូវបាន “ល្បងលដោយភ្លើង” ដូចមានពន្យល់ស្រាប់នៅក្នុង ១ កូរិនថូស ៣:១០-១៥ និង ២ កូរិនថូស ៥:១០ ។ កិច្ចការដែលយើងធ្វើដោយជំនឿ និង ដោយប្រតិបត្តិតាមព្រះអម្ចាស់ ប្រៀបដូចជាត្បូងដ៏មានតំលៃ និងមាសដែលនឹងមិនត្រូវឆេះទេ ។ ប៉ុន្តែ បើយើងធ្វើកិច្ចការដែលយើងមិនគួរធ្វើ កិច្ចការនោះនឹងត្រូវឆេះដោយសារភ្លើងល្បងល ហើយយើងនឹងមិនបានទទួលរង្វាន់សំរាប់កិច្ចការទាំងនេះឡើយ ។



ទីបន្ទាល់ដែលមានប្រសិទ្ធិភាពជាងគេ គឺនិយាយអំពី :

☐ ព្រះគ្រីស្ត (ព្រះអង្គជាអ្នកណា ពីកិច្ចការដែលព្រះអង្គធ្វើ និងពីរបៀបដែលព្រះអង្គសង្គ្រោះយើង) ។

☐ សេចក្តីជ្រៅៗអំពីសាសនា ។

☐ អំពីជីវិតចាស់ដែលអាក្រក់របស់យើង ។

ការប្រកាសដំណឹងល្អ ដែលនាំអោយមនុស្សជឿ គឺនិយាយប្រាប់ពីព្រះយេស៊ូគ្រីស្តជាអ្នកណា ពីកិច្ចការដែលព្រះអង្គបានធ្វើ និងពីរបៀបដែលព្រះអង្គសង្គ្រោះយើង (លូកា ២៤:៤៥-៤៨) ។

ពេលដែលអ្នកជឿពិតធ្វើកិច្ចការខាងសាច់ឈាម ដែលមិនគាប់ព្រះហឫទ័យព្រះជាម្ចាស់ តើយើងនឹងបាត់បង់អ្វីខ្លះ ?

☐ រង្វាន់ខ្លះដែលយើងត្រូវបាននៅស្ថានសួគ៌ ។

☐ ជីវិតអស់កល្ប ។

☐ គ្មានបាត់បង់អ្វីទេ ។

អំពើល្អនិមួយៗសុទ្ធតែមានរង្វាន់ ប៉ុន្តែ បើសិនជាយើងមិនបានធ្វើអំពើល្អទាំងនោះ ព្រះគ្រីស្តនឹងមិនប្រទានរង្វាន់សំរាប់អំពើទាំងនោះអោយយើងទេ ។





សូមមើលសេចក្តីដែលព្រះគ្រីស្តបង្គាប់ អោយយើង ប្រតិបត្តិតាមម្តងទៀត ។

១- កែប្រែចិត្តគំនិត ជឿ និងទទួលព្រះវិញ្ញាណ-ដ៏វិសុទ្ធ (ការសង្គ្រោះ) ។

២- ទទួលពិធីជ្រមុជទឹក (ចាប់ផ្តើមរស់នៅដោយមានជីវិតថ្មី) ។

៣- ស្រឡាញ់ព្រះជាម្ចាស់ និងអ្នកឯទៀត ។

៤- អធិស្ឋាន និងរៀនព្រះបន្ទូលព្រះជាម្ចាស់ ។

៥- ជួបជុំគ្នា និងធ្វើពិធីកាច់នំបុ័ង ។

៦- ចែកចាយ និងថ្វាយដង្វាយ ។

៧- បង្កើតសាវ័ក ដោយផ្សាយដំណឹងល្អ និង បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។



របស់យើងអោយស្គាល់ព្រះគ្រីស្ត តាមរយៈសេចក្តីស្រឡាញ់របស់យើងចំពោះពួកគេទាំងនោះ ។ បើយើងគ្មានសេចក្តីស្រឡាញ់ទេ មនុស្សនឹងមានចិត្តរឹងកាន់តែខ្លាំងឡើងៗ ។



តើសេចក្តីបង្គាប់ណាមួយដែលអ្នកពិតជាត្រូវខិតខំបំពេញ អោយកាន់តែប្រសើរ ?

- ☐ កែប្រែចិត្តគំនិត ជឿ និង ទទួលព្រះវិញ្ញាណដ៏វិសុទ្ធ (ការសង្គ្រោះ) ។
- ☐ ទទួលពិធីជ្រមុជទឹក (ចាប់ផ្តើមរស់នៅដោយមានជីវិតថ្មី) ។
- ☐ ស្រឡាញ់ព្រះជាម្ចាស់ និង អ្នកឯទៀត ។
- ☐ អធិស្ឋាន និង រៀនព្រះបន្ទូលព្រះជាម្ចាស់ ។
- ☐ ជួបជុំគ្នា និង ធ្វើពិធីកាច់នំប៉័ង ។
- ☐ ចែកចាយ និង ថ្វាយដង្វាយ ។
- ☐ បង្កើតសាវ័ក ដោយផ្សាយដំណឹងល្អ និង បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

© Project WorldReach © SEAN

ប៉ុន្តែ ខ្ញុំអត់ចេះអានទេ លោកគ្រូ តើខ្ញុំអាចសិក្សាព្រះបន្ទូលព្រះជាម្ចាស់ ដោយរបៀបណា ?



ប្អូនស្រី ទៅចូលរួមក្នុងការប្រជុំ ដែលគេបង្រៀនព្រះ-បន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីស្តាប់ រួចរិះគិតពិចារណាពីព្រះបន្ទូលនោះ ។ សូមអោយចេះគិតពីព្រះជាម្ចាស់ គឺពីសេចក្តីសុចរិត សេចក្តីស្រឡាញ់ដ៏ធំធេង សេចក្តីប្រាជ្ញា និងទ្ធានុភាពរបស់ព្រះអង្គ ។ ក្រៅពីនេះ សូមរៀនអោយចេះអានផងដែរ ។ ឥឡូវនេះ យើងនឹងមើលពីភារៈកិច្ចទាំងប្រាំពីរម្តងទៀត ។

ទេ មិនពិបាកទេ គឺស្រួលធ្វើ បើសិនជាយើងធ្វើដោយសេចក្តីស្រឡាញ់ និងពឹងលើព្រះវិញ្ញាណដ៏វិសុទ្ធ ដែលប្រទានឲ្យយើងមានឫទ្ធានុភាព ។ ជាពិសេស ការផ្សាយដំណឹងល្អមិនសូវពិបាក បើសិនជាយើងផ្សព្វផ្សាយក្នុងចំណោមមិត្តភក្តិ និងសាច់ញាតិរបស់យើង ។



ការផ្សាយដំណឹងល្អអំពីព្រះគ្រីស្តស្រួលធ្វើ បើយើងធ្វើ ដោយ :

☐ សេចក្តីស្រឡាញ់ ។

☐ បង្ខំចិត្តអ្នកស្តាប់ ។

ការផ្សាយដំណឹងល្អស្រួលធ្វើ បើសិនជាយើងធ្វើដោយសេចក្តីស្រឡាញ់ ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងនាំសាច់ញាតិ និងមិត្តភក្តិ

© Project WorldReach © SEAN

ការដាក់ដង្វាយថ្វាយព្រះជាម្ចាស់ ជាផ្នែកមួយនៃការថ្វាយបង្គំ
ជាមួយក្រុមជំនុំ ។



តើអ្នកអាចសូត្រពីសេចក្តីបង្គាប់សំខាន់ទាំងប្រាំពីរ ដោយមិនបាច់
អានបានឬទេ ?

☐ បាន ។

☐ មិនបានទេ ។

បើសិនជាមិនបានទេ សូមទន្ទេញសេចក្តីបង្គាប់ទាំងនោះ អោយ
ចាំនៅពេលនេះ ។



ភារៈកិច្ចសំខាន់បំផុតសំរាប់សមាជិកក្រុមជំនុំ គឺត្រូវចេះស្រឡាញ់ ។ នេះជាសេចក្តីបង្គាប់ដ៏ធំបំផុតរបស់ព្រះជាម្ចាស់ ។

យើងត្រូវថ្វាយបង្គំព្រះជាម្ចាស់ជាប់ជានិច្ច ។ បើយើងគ្មានសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ យើងក៏លែងមានសេចក្តីស្រឡាញ់ចំពោះមនុស្សឯទៀតដែរ ។



២ កូរិនថូស ៩:៦-៧ ចែងថា៖ *“អ្នកណាព្រោះតិច អ្នកនោះក៏ច្រូតបានផលតិចដែរ រីឯអ្នកដែលព្រោះច្រើនបរិបូណ៌ ក៏ច្រូតបានផលច្រើនបរិបូណ៌ដែរ ។ ហេតុនេះ ម្នាក់ៗត្រូវតែចូលប្រាក់ តាមតែខ្លួនសំរេចចិត្ត ដោយមិននឹកស្តាយ ឬ ទើសទ័លឡើយ ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកណា ដែលធ្វើអំណោយដោយចិត្តរីករាយ”* ។



ការថ្វាយដង្វាយ ជាផ្នែកមួយនៃការថ្វាយបង្គំព្រះជាម្ចាស់ ហេតុនេះហើយបានជាយើងត្រូវ :

☐ ជួយតែមិត្តភក្តិរបស់យើងដែលខ្វះខាត ឃ្យរៗម្តងប៉ុណ្ណោះ ។

☐ ដាក់ដង្វាយដប់ភាគរយ នៅពេលដែលយើងចូលរួមថ្វាយបង្គំជាមួយក្រុមជំនុំ ។

ប៉ុន្តែ អ្នកជឿខ្លះមិនស្លូតបូតសោះ ។ តើឱ្យខ្ញុំអាចមានចិត្តស្រឡាញ់ពួកគេ កាន់តែខ្លាំងដូចម្តេចបាន ?



សេចក្តីស្រឡាញ់ជាផលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលគង់សណ្ឋិតក្នុងយើង (កាឡាទី ៥:២២) ។ ព្រះអង្គជួយយើងអោយចេះបង្ហាញសេចក្តីស្រឡាញ់ ។ យើងមិនអាចមានសេចក្តីស្រឡាញ់ ដោយខ្លួនឯងបានទេ ។ ដូច្នេះ សូមអោយព្រះវិញ្ញាណដ៏វិសុទ្ធបំពេញអ្នកជាប់ជាប្រចាំ ។



នៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ម៉ាឡាគី ៣:៨ ប្រាប់យើងថា បើសិនជាយើងមិនថ្វាយដង្វាយដប់ភាគរយទេនោះ គឺយើងកេងប្រវ័ញ្ចព្រះជាម្ចាស់ហើយ ។ ឥឡូវនេះ យោងទៅតាមសម្ពន្ធមេត្រីថ្មី យើងលែងនៅក្រោមអំណាចក្រិត្យវិន័យទៀតហើយ ។ ទោះបីជាយើងមិនដាក់ដង្វាយដប់ភាគរយតាមក្រិត្យវិន័យក៏ដោយ ក៏យើងដាក់ដង្វាយ មកពីយើងមានសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ដែរ ហើយការដាក់ដង្វាយមានប្រយោជន៍បំផុត ។



ខ្ញុំស្រឡាញ់បងប្អូនរបស់ខ្ញុំក្នុងព្រះគ្រីស្តទាំងអស់ បើសិនជាពួកគេល្អនឹងខ្ញុំណា៎ ។



ប៉ុន្តែ ប្អូនប្រុស គេមើលឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងយើង ជាពិសេស នៅពេលដែលយើងបង្ហាញសេចក្តីស្រឡាញ់ដល់មនុស្សដែលធ្វើខុសមកលើយើងណា៎ !

យើងស្រួលមានសេចក្តីស្រឡាញ់ចំពោះអ្នកដែលធ្វើល្អនឹងយើង ។ សូម្បីតែអ្នកមិនទាន់ជឿ និងឧក្រិដ្ឋជន ក៏ចេះស្រឡាញ់គ្នាគេទៅវិញទៅមកដែរ បើសិនជាពួកគេមានទំនាក់ទំនងល្អជាមួយគ្នា ។

តើយើងដាក់ដង្វាយថ្វាយព្រះជាម្ចាស់ ដោយរបៀបណា ?

☐ ដោយស្មាក់ស្ទើរ ។

☐ តែអ្វីដែលយើងនៅសល់ ។

☐ ដោយអំណរ ។

យើងដាក់ដង្វាយថ្វាយព្រះជាម្ចាស់ដោយអំណរ ។ អ្វីៗទាំងអស់ដែលយើងមាន គឺព្រះជាម្ចាស់ប្រទានឱ្យ ។ ព្រះជាម្ចាស់បង្កើតអ្វីៗសព្វសារពើ ហើយព្រះអង្គផ្គត់ផ្គង់អ្វីៗគ្រប់យ៉ាង ។ ព្រះអង្គជាម្ចាស់លើអ្វីៗគ្រប់យ៉ាងទាំងអស់ រួមទាំងយើងទៀតផង ។ ព្រះអង្គរំដោះយើង ដោយសារព្រះលោហិតរបស់ព្រះគ្រីស្ត ។ យើងរាល់គ្នា និង របស់គ្រប់យ៉ាងដែលយើងមាន ជារបស់ផងព្រះជាម្ចាស់ ។

© Project WorldReach © SEAN

ប៉ុន្តែ តើយើងអាចមានសេចក្តីស្រឡាញ់ចំពោះអ្នកដែលធ្វើអាក្រក់មកលើយើងដូចម្តេចបាន ?



ដោយសារព្រះចេស្តារបស់ព្រះគ្រីស្ត ។ ព្រះអង្គបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដោយអត់ទោសឱ្យពួកអ្នកដែលវាយ និងឆ្កាងព្រះអង្គ ។ យើងក៏ត្រូវអត់ទោស និងស្រឡាញ់ពួកអ្នកដែលធ្វើអាក្រក់មកលើយើង ដូចព្រះអង្គដែរ ។

យើងបង្ហាញសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត :

- ☐ **តែពេលដែលយើងនៅជាមួយគ្រីស្តជនស្មោះត្រង់ ដែលប្រព្រឹត្តល្អចំពោះយើង ។**
- ☐ **ដោយអត់ទោស និងធ្វើល្អចំពោះអ្នកដែលធ្វើអាក្រក់មកលើយើង ។**

សារឿន ! បងឯងកំណាញ់ណាស់ ! បើបងយកប្រាក់ទៅជាក់ជង្វាយ បងគ្មានលុយគ្រប់គ្រាន់សំរាប់ទិញខ្សែកអោយខ្ញុំទេ ។



តែឥឡូវនេះ បងជាអ្នកជឿណា៎ ! បងមានបំណងណែនាំក្រុមគ្រួសាររបស់យើងអោយចេះស្រឡាញ់ និងបំរើព្រះយេស៊ូ ដោយអស់ពីចិត្ត ។ បងចង់អោយយើងចេះប្រើសំភារៈរបស់ទ្រព្យ ដើម្បីបំរើព្រះអង្គ ។ ជំបូង បងនឹងជាក់ជង្វាយថ្វាយព្រះជាម្ចាស់ ដោយអំណរសិន ហើយថៃក្រោយ បងនឹងទិញខ្សែកអោយអូនណា៎ ។

យើងត្រូវអត់ទោស និង ស្រឡាញ់ទាំងសត្រូវរបស់យើងទៀត (អេភេសូ ៤:៣២, រ៉ូម ៥:៨, ១២:១៤-២១) ។







ដង្វាយដប់ភាគរយ ជាចំនួនមួយភាគដប់នៃ :

☐ ប្រាក់របស់យើងតែប៉ុណ្ណោះ ។

☐ ចំណូលទាំងអស់របស់យើង ជាផលិតផល ឬ ជាប្រាក់កាស ។

ដង្វាយដប់ភាគរយ ជាចំនួនមួយភាគដប់នៃចំណូលរបស់យើង ជាប្រាក់កាស ឬ ជាផលិតផល ។

ត្រូវហើយ ! ការធ្វើពិធីកាច់នំបុ័ងបង្ហាញពីជំនឿរបស់យើងលើព្រះគ្រីស្ត ដោយរួមប្រកបគ្នាជាមួយក្រុមជំនុំ ដែលជាព្រះកាយរបស់ព្រះអង្គ ។ យើងត្រូវពិនិត្យពិចារណាមើលចិត្តគំនិតយើងសិន មុននឹងចូលរួមក្នុងពិធីកាច់នំបុ័ង ។ គឺយើងអធិស្ឋានលន់តួសារភាពអំពើបាបរបស់យើងថ្វាយព្រះជាម្ចាស់រួច ទើបយើងចូលរួមក្នុងពិធីកាច់នំបុ័ងតាមរបៀបសមរម្យ ។ លោកប៉ុលបានមានប្រសាសន៍ប្រាប់ នៅក្នុងបទគម្ពីរ ១ កូរិនថូស ១១:២៧-៣២ថា បើយើងធ្វើពិធីកាច់នំបុ័ង ដោយមិនយល់ និង មិនគោរពដល់ព្រះកាយរបស់ព្រះអម្ចាស់ទេ នោះយើងយកទោសមកដាក់លើខ្លួនឯងហើយ ។ វគ្គគម្ពីរនេះប្រាប់យើងទៀតថា ព្រះជាម្ចាស់ប្រៀនប្រដៅយើង ដើម្បីកុំអោយយើងជាប់ទោសជាមួយលោកីយ៍នេះ ។ លោកប៉ុលមានប្រសាសន៍ដែរថា នៅពេលដែលយើងចូលរួមធ្វើពិធីកាច់នំបុ័ង យើងរំលឹកអំពីការសុគតរបស់ព្រះអម្ចាស់ និងចូលរួមក្នុងព្រះកាយរបស់ព្រះអង្គ និងព្រះលោហិតរបស់ព្រះអង្គ ។



© Project WorldReach © SEAN

សូមទៅចូលរួមប្រជុំថ្វាយបង្គំគ្រប់ពេល ។ ព្រោះនេះជាការៈកិច្ច និងឯកសិទ្ធិពិសេសរបស់សមាជិកគ្រប់រូប ។ (ហេប្រឺ ១០:២៤-២៥)



ប៉ុន្តែ នៅពេលខ្លះ មានការអ៊ូអរពេកក្នុងព្រះវិហារ ធ្វើអោយខ្ញុំបែកអារម្មណ៍ មិនអាចរិះគិតពិចារណាអំពីព្រះជាម្ចាស់បានសោះ ។

តើយើងត្រូវធ្វើអ្វី មុននឹងចូលរួមធ្វើពិធីកាច់នំបុ័ង ?

☐ **អានទំនុកតម្កើងមួយ ។**

☐ **អធិស្ឋានលន់តួសារភាពបាបរបស់យើងទៅព្រះជាម្ចាស់ ។**

មុននឹងចូលរួមធ្វើពិធីកាច់នំបុ័ង យើងត្រូវពិនិត្យមើលចិត្តរបស់យើងនៅចំពោះព្រះជាម្ចាស់ និងអធិស្ឋានលន់តួសារភាពអំពើបាបរបស់យើងជាមុនសិន ១ កូរិនថូស ១១:២៧-៣២ ។

ដង្វាយដប់ភាគរយ មានចំនួនស្មើនឹងមួយភាគដប់នៃប្រាក់ចំណូលរបស់យើង ។ នៅក្នុងសម័យសម្ពន្ធមេត្រីចាស់ គេយកមួយភាគដប់នៃផលិតផល ដែលគេធ្វើបាន ទៅថ្វាយព្រះជាម្ចាស់ ។



© Project WorldReach © SEAN

ព្រះគម្ពីរជាព្រះបន្ទូលព្រះជាម្ចាស់ ។ ព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺចិត្តគំនិតមនុស្សមួយចំនួនអោយតែងព្រះគម្ពីរ ។ ព្រះអង្គដឹកនាំពួកគេអោយសរសេរដោយគ្មានកំហុស ។ ពួកគេសរសេរតាមរបៀបពួកគេផ្ទាល់ ប៉ុន្តែ ព្រះវិញ្ញាណនៃព្រះជាម្ចាស់បំភ្លឺពួកគេអោយសរសេរ (២ ធីម៉ូថេ ៣:១៦, ២ ពេត្រុស ១:២០-២១)។



យើងសង្ឃឹមថា សមាជិកក្រុមជំនុំចេះគិតគូរពីអ្នកជំងឺនៅពេលថ្វាយបង្គំជាមួយគ្នា ។ យើងត្រូវចូលទៅក្នុងព្រះវិហារដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ដោយស្ងៀមស្ងាត់ និងដោយគោរព (ហាបាគូក ២:២០) ។ យើងត្រូវទៅអង្គុយនៅខាងមុខ ទុកកន្លែងខាងក្រោយអោយអ្នកមកយឺតអង្គុយ ។ ការដើរទៅខាងមុខ នៅពេលដែលក្រុមជំនុំកំពុងថ្វាយបង្គំ នាំអោយរំខានដល់អ្នកជំងឺ ។



ជួនកាលខ្ញុំនិយាយគ្នាទៅវិញទៅមក ពេលគ្រូគង្វាលកំពុងបង្រៀនព្រះបន្ទូល ។ ប៉ុន្តែ ឥឡូវនេះ ខ្ញុំនឹងនៅស្ងៀមហើយទុកពេលវេលានោះស្តាប់ព្រះបន្ទូល និងគោរពបងប្អូនឯទៀត ដែលកំពុងស្តាប់វិញ ។

ប៉ុន្តែ តើយើងអាចស្វាគមន៍សមាជិកដែលមកយឺតនៅពេលណាទៅ ?



ក្រោយពិធីថ្វាយបង្គំ សមាជិកទាំងអស់ត្រូវស្វាគមន៍គ្នា និងនិយាយគ្នាទៅវិញទៅមក ។ សំខាន់បំផុត គឺត្រូវស្វាគមន៍អ្នកជឿថ្មី និងភ្ញៀវ ។

សមាជិករបស់ក្រុមជំនុំគ្រប់រូបមានភារៈកិច្ច និងមានសិទ្ធិចូលរួមធ្វើពិធីកាច់នំប៉័ង ។ យើងត្រូវធ្វើពិធីកាច់នំប៉័ង ដើម្បី :

☐ សន្សំកុសលផលបុណ្យ ។

ហេតុអ្វីក៏ការសិក្សាព្រះគម្ពីរសំខាន់ដូចនេះ ? តើមានសៀវភៅណាផ្សេងទៀត ដែលស្រួលជាងព្រះគម្ពីរឬទេ ?



ព្រះគម្ពីរជាសៀវភៅតែមួយដែលព្រះជាម្ចាស់បណ្តាលឱ្យសរសេរ ។ សៀវភៅផ្សេងៗអាចជួយអ្នក អោយកាន់តែយល់ព្រះគម្ពីរ តែគ្មានសៀវភៅណាអាចជំនួសព្រះគម្ពីរបានទេ ។

ហេតុអ្វីបានជាយើងត្រូវរិះគិតពិចារណាពីព្រះគម្ពីរ ?

☐ ព្រោះព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

☐ ព្រោះព្រះគម្ពីរជាពាក្យសំដីរបស់មនុស្សប្រាជ្ញាបំផុត ។



- ☐ ធ្វើអោយយើងបាត់ឃ្លាន ។
- ☐ អោយយើងអាចរួមចិត្តគំនិតយ៉ាងជ្រាលជ្រៅជាមួយព្រះ-គ្រីស្ត និង អ្នកដទៃ ។

គ្រីស្តជនត្រូវរួមរស់សមប្រកបជាមួយព្រះជាម្ចាស់ជាប់ជានិច្ច ។ អ្វីៗគ្រប់យ៉ាងដែលរារាំងយើង មិនអោយមានការរួមរស់សមប្រកបជាមួយព្រះជាម្ចាស់ សុទ្ធតែជាអំពើបាប ។

ដើម្បីឱ្យយើងមានការរួមរស់សមប្រកបជាមួយព្រះជាម្ចាស់ និងបានពោរពេញដោយព្រះវិញ្ញាណ ជាប់ជានិច្ចនោះ យើងត្រូវ :

- ☐ អធិស្ឋានលន់តួសារភាពអំពើបាប ហើយប្រតិបត្តិតាមព្រះគ្រីស្តដោយជំនឿ និង ដោយសេចក្តីស្រឡាញ់ ។
- ☐ ធ្វើបុណ្យច្រើនរបស់មនុស្សលោក ។
- ☐ មានការរំជួលចិត្តខ្លាំង រាល់ពេលដែលយើងជួបជុំគ្នា ។

នៅពេលដែលអ្នកជឿលើព្រះយេស៊ូបានប្រព្រឹត្តអំពើបាប គេត្រូវទទួលសារភាពអំពើបាបនោះ និងកែប្រែចិត្តគំនិតភ្លាមៗ (១ យ៉ូហាន ១:៩) ។

ការៈកិច្ចមួយទៀត គឺអធិស្ឋាន ហើយអាន និងរិះគិត
ពិចារណាពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ នៅពេល
ដែលយើងអធិស្ឋាន គឺយើងមានទំនាក់ទំនងសមប្រកប
ជាមួយព្រះជាម្ចាស់ ។ នៅពេលដែលយើងរិះគិត
ពិចារណាពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះជាម្ចាស់មាន
ព្រះបន្ទូលមកកាន់យើង ។ សូមចាត់ទុកព្រះជាម្ចាស់ជា
ទីមួយក្នុងជីវិតរបស់យើងរាល់គ្នា ។ ពីព្រោះព្រះជា-
ម្ចាស់បង្កើតមនុស្សមក ដើម្បីថ្វាយសិរីរុងរឿងដល់ព្រះ-
អង្គ និង ដើម្បីអោយគេរួមប្រកបជាមួយព្រះអង្គជា
រៀងរហូត (អេសាយ ៤៣:៧, យ៉ូហាន ៤:២៤) ។
តើអ្នកទាំងពីរចេះអធិស្ឋានដែរឬទេ ?



ក្រៅពីការអធិស្ឋានផ្ទាល់ខ្លួន យើងត្រូវអធិស្ឋាន និងរិះគិត
ពិចារណាពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមួយ :

☐ ក្រុមគ្រួសារ ។

☐ មនុស្សមិនធ្លាប់ស្គាល់ ។

☐ អ្នកជិតខាង ។

☐ គ្រូគង្វាល ។

ព្រះជាម្ចាស់បង្គាប់យើងអោយបង្រៀនក្រុមគ្រួសារយើងអោយចេះ
ស្តាប់ព្រះជាម្ចាស់ (យ៉ូស្វ៊ីអា ២៤:១៥, ទុតិយកថា ៦:៦-៧) ។
ក្រុមគ្រួសារ ដែលជឿលើព្រះយេស៊ូ មានប្រយោជន៍ដល់
សហគមន៍ ។

ចេះលោកគ្រូ ។ លោកគ្រូបានបង្រៀនយើងរួចហើយ ។



យើងត្រូវអធិស្ឋានពេលព្រឹក ដើម្បីយកឱកាស ទូលសូម
អោយព្រះជាម្ចាស់ធ្វើជាម្ចាស់លើចិត្តគំនិត កិច្ចការ និង
អ្វីៗទាំងអស់ដែលយើងនឹងធ្វើ ឬ ជួបប្រទះនៅក្នុងថៃនោះ
(អេភេសូ ៥:១៥-១៦) ។



កូនៗអាចនឹងស្គាល់ព្រះគ្រីស្ត ដោយសារគំរូរបស់ប្អូន ។
យើងត្រូវអធិស្ឋានជាមួយកូនៗអោយបានរាល់ថៃ ។
អ្នកទាំងអស់គ្នាត្រូវការចំណីអាហារខាងព្រលឹងវិញ្ញាណ
ជារៀងរាល់ថៃ ។ ចំណីអាហារនេះ បានមកដោយ
សារការអធិស្ឋាន និងអានព្រះបន្ទូលព្រះជាម្ចាស់ ។
យើងត្រូវអាន រិះគិតពិចារណា និងប្រតិបត្តិតាមព្រះ-
បន្ទូល ។ ការអធិស្ឋានសំខាន់ដូចការដកដង្ហើមដែរ ។
យើងត្រូវសរសើរដំកើងព្រះជាម្ចាស់ជារៀងរាល់ថៃ និង
ទូលសូមសំរាប់សេចក្តីត្រូវការរបស់មនុស្សឯទៀត និង
របស់ខ្លួនឯងផ្ទាល់ ។



តើយើងត្រូវអធិស្ឋានថ្វាយថ្ងៃថ្មី ទៅព្រះជាម្ចាស់នៅពេលណា ?

☐ នៅពេលដែលយើងមានសេចក្តីត្រូវការ ។

☐ នៅពេលថ្ងៃត្រង់ ។

☐ នៅពេលព្រឹកព្រលឹម ។

ព្រះអម្ចាស់យេស៊ូគ្រីស្តអធិស្ឋានពេលព្រឹកព្រលឹម (ម៉ាកុស ១:៣៥) ។ សូមយើងធ្វើតាមគំរូរបស់ព្រះអង្គ ។





